# ការកំណត់ឡើងវិញនូវ ពាក្យសម្ងាត់ប្រព័ន្ធ ជ្រើសរើសសាលារៀន របស់អ្នក សម្រាប់អ្នកដាក់ពាក្យជាសិស្សក្រៅមណ្ឌលសិក្សាធិការ

សិស្ស និងមាតាបិតា/អាណាព្យាបាលដែលមានបំណងចង់ចូលរួមនៅក្នុងដំណើរការជ្រើសរើសសាលារៀនរបស់ School District of Philadelphia នឹងប្រើប្រាស់ប្រព័ន្ធអនឡាញដើម្បីដាក់ពាក្យ។ មាតាបិតា/អាណាព្យាបាលរបស់សិស្សក្រៅមណ្ឌលសិក្សាធិការត្រូវតែបង្កើតគណនី ដើម្បីចូលប្រ?ពាក្យសុំតាមអនឡាញ។

ដើម្បីស្វែងយល់បន្ថែមអំពីបទបញ្ញត្តិ នីតិវិធី និងលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានសម្រាប់ដំណើរការជ្រើសរើសសាលារៀនរបស់ School District of Philadelphia សូមចូលមើលគេហទំព័រ https://www.philasd.org/findyourfit។

ក្រោយបង្កើតគណនីរបស់អ្នកហើយ សូមធ្វើតាមការណែនាំនៅក្នុងជំហានចាប់ផ្តើម ពាក្យសុំជ្រើសរើសសាលារៀនសម្រាប់
អ្នកដាក់ពាក្យជាសិស្សក្រៅមណ្ឌលសិក្សាធិការ ដើម្បីបង្កើត និងដាក់ពាក្យសុំរបស់អ្នក។

## *ការកំណត់ពាក្យសម្ងាត់ឡើងវិញរបស់អ្នក*

1. ដើម្បីកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ សូមបញ្ចូលអាសយដ្ឋានអ៊ីមែល ដែលអ្នកបានប្រើដើម្បីបង្កើតគណនី បន្ទាប់មកចុចលើតំណខ្ពស់ *Forgot password? (ភ្លេចពាក្យសម្ងាត់ឬ?)*។



2. បញ្ចូលអ៊ីមែលដែលអ្នកបានប្រើ ដើម្បីបង្កើតគណនី បន្ទាប់មកចុចលើ ***Continue (បន្ត)***។




3. សារមួយនឹងបង្ហាញដែលជូនដំណឹងអ្នកឲ្យ *‘សូមពិនិត្យអាសយដ្ឋានអ៊ីមែលរបស់អ្នករកមើលការណែនាំ ដើម្បីកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ។*




4. ពិនិត្យអ៊ីមែលរបស់អ្នករកមើលតំណកំណត់ឡើងវិញ។ ចុចលើតំណ ***Reset password (កំណត់ពាក្យសម្ងាត់ឡើងវិញ)***។



5. ទំព័រ **Reset Password (កំណត់ពាក្យសម្ងាត់ឡើងវិញ)** បើក។ បញ្ចូលពាក្យសម្ងាត់ថ្មី បញ្ជាក់ពាក្យសម្ងាត់ ចុចលើ ***arrow (សញ្ញាព្រួញ)*** នៅក្នុងប្រអប់ពណ៌ស្វាយដើម្បីកំណត់ពាក្យសម្ងាត់ឡើងវិញ។




## <u>គាំទ្រសម្រាប់គណនីដែលបង្កើតតាមទូរសព្ទ</u>

បើគណនីត្រូវបានបង្កើតតាមទូរសព្ទ ហើយអ្នកមិនអាចចូលប្រើលេខទូរសព្ទដែលបានផ្តល់ជូនបានទៀតទេ សូមទាក់ទងតាម familytechsupport@philasd.org ដើម្បីស្នើសុំជំនួយគាំទ្រជាមួយនឹងការធ្វើបច្ចុប្បន្នភាពលេខ ទូរសព្ទរបស់អ្នក។